# សេចក្តីថ្លែងការណ៍ជំហររបស់ព្រះរាជាណាចក្រកម្ពុជា សម្រាប់សន្និសីទលើកទី១៩ នៃអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ នៅទីក្រុងវ៉ារស្សូវី ប្រទេសប៉ូឡូញ

ថ្ងៃទី១១ ដល់ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៣

ក្នុងនាមជាភាគីនៃអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (United Nations Framework Convention on Climate Change: UNFCCC) កម្ពុជាគាំទ្រយ៉ាងពេញទំហឹងចំពោះកិច្ចប្រឹងប្រែងនានាក្នុងការឆ្លើយតបចំពោះបញ្ហាប្រែប្រួលអាកាសធាតុ ដោយផ្អែកលើគោលការណ៍ចម្បងៗនៃអនុសញ្ញា UNFCCC។ បន្ថែមលើនេះ ជំហរចរចារបស់ព្រះរាជាណាចក្រកម្ពុជា គឺស្របទៅតាមជំហររបស់ក្រុមប្រទេសអភិវឌ្ឍតិចតួច (Least Developed Countries: LDCs) និងក្រុមប្រទេស G77 និងចិន (G77+China)។

1. កម្ពុជាអំពាវនាវដល់ភាគីទាំងអស់ថា រាល់សកម្មភាព ឬវិធានការនានា ដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ ត្រូវតែអនុលោមទាំងស្រុងទៅតាមគោលការណ៍ និងគោលដៅនានារបស់អនុសញ្ញាក្រមខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ ជាពិសេសគោលការណ៍ សមធម៌ ការទទួលខុសត្រូវជាប្រវត្តិសាស្ត្រ ការទទួលខុសត្រូវរួមប៉ុន្តែនៅក្នុងកម្រិតផ្សេងគ្នា ទៅតាមសមត្ថភាពប្រទេសនីមួយៗ និងធានាឲ្យបាននូវការអភិវឌ្ឍដោយចីរភាពនៃបណ្តាប្រទេសកំពុងអភិវឌ្ឍ។
2. កម្ពុជាទទួលស្គាល់ថា កំណើនសីតុណ្ហភាពនឹងនាំឱ្យមានផលប៉ះពាល់ដ៏មហន្តរាយដល់ប្រទេសទាំងអស់ ជាពិសេសបណ្តាប្រទេសអភិវឌ្ឍតិចតួច ដោយសារតែសមត្ថភាព និងលទ្ធភាពបន្សាំរបស់ពួកគេនៅមានកម្រិតទាប។
3. កម្ពុជាអំពាវនាវដល់ភាគីទាំងអស់ឱ្យយកចិត្តទុកដាក់លើតម្រូវការជាក់លាក់ និងស្ថានភាពពិសេសជាច់ដោយឡែករបស់បណ្តាប្រទេសអភិវឌ្ឍតិចតួច នៅក្នុងសកម្មភាពរបស់ខ្លួន ទាក់ទងទៅនឹងការផ្តល់មូលនិធិ និងការផ្ទេរបច្ចេកវិទ្យា ដោយអនុលោមតាមមាត្រា ៤.៩ នៃអនុសញ្ញា UNFCCC។
4. កម្ពុជាអំពាវនាវដល់បណ្តាភាគីនៅក្នុងឧបសម្ព័ន្ធទី១ ទាំងអស់ ឱ្យពង្រឹងការប្តេជ្ញាចិត្តផ្នែកនយោបាយ ភាពជាអ្នកដឹកនាំ និងឆន្ទៈ ក្នុងការបង្កើនមហិច្ឆតានៃកម្រិតកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់របស់ខ្លួន សម្រាប់រយៈពេលមុនឆ្នាំ២០២០ ក្នុងទិសដៅរក្សាកំណើនសីតុណ្ហភាពមធ្យមសកល ឲ្យស្ថិតនៅក្រោម១,៥ អង្សាសេលស៊ុសត្រឹមឆ្នាំ២១០០ ធៀបទៅនឹងកម្រិតសីតុណ្ហភាពមធ្យមនៅមុនសម័យបដិវត្តន៍ឧស្សាហកម្ម។
5. កម្ពុជាអំពាវនាវដល់ភាគីទាំងអស់ ឲ្យស្វែងយល់ពីស្ថានភាពបន្ទាន់នៃការងាររៀបចំកិច្ចព្រមព្រៀងអាកាសធាតុថ្មីនៅឆ្នាំ២០១៥ ដែលត្រូវតែបញ្ចូលនូវការប្តេជ្ញាចិត្តដ៏ទូលំទូលាយរបស់ភាគីទាំងអស់ ជាពិសេសតួនាទីជាអ្នកដឹកនាំរបស់បណ្តាប្រទេសអភិវឌ្ឍន៍ ក៏ដូចជាបណ្តាប្រទេសកំពុងអភិវឌ្ឍ ដើម្បីរួមចំណែកដល់សកម្មភាពឆ្លើយតបនឹងអាកាសធាតុពិភពលោក ដូចមានចែងនៅក្នុងមាត្រា៤.៧ នៃអនុសញ្ញា UNFCCC។
6. កម្ពុជាគាំទ្រដល់ការប្តេជ្ញាចិត្តក្នុងការអនុវត្តសកម្មភាពបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ និងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ទាំងអស់ ដែលគួរទទួលនូវអាទិភាពស្មើគ្នា សម្រាប់កិច្ចព្រមព្រៀងអាកាសធាតុនាពេលអនាគត។
7. កម្ពុជាសូមជម្រុញដល់ការអនុវត្តក្របខ័ណ្ឌការងារបន្សាំ ដែលបានបង្កើតឡើងនៅទីក្រុងកាំគុន និងបទបញ្ញត្តិនានា សម្រាប់ដំណើរការរៀបចំ និងអនុវត្តផែនការបន្សាំថ្នាក់ជាតិ (National Adaptation Plans: NAPs)

នៅបណ្តាប្រទេសអភិវឌ្ឍតិចតួច ក៏ដូចជាកម្មវិធីការងារទាក់ទងនឹងការបាត់បង់ និងការខូចខាត (Work Programmes on Loss & Damage) ដោយផ្អែកទៅលើអាទិភាពនានា របស់ប្រទេសនីមួយៗ។

8. កម្ពុជាជម្រុញឲ្យបណ្តាភាគីប្រទេសអភិវឌ្ឍន៍ ដៃគូអភិវឌ្ឍន៍ អង្គការនានារបស់សហប្រជាជាតិ និងអង្គការអន្តរជាតិនានា ផ្តល់ការគាំទ្រផ្នែកបច្ចេកទេស និងថវិកាឲ្យបានគ្រប់គ្រាន់ ដែលអាចទទួលបានដោយងាយស្រួល និងតាមនីតិវិធីអាចបត់បែនបាន សម្រាប់ការរៀបចំ និងអនុវត្តផែនការបន្ស៊ាំថ្នាក់ជាតិ ដោយគ្មានការពន្យារពេល។

9. កម្ពុជាគាំទ្រដល់ការបង្កើតយន្តការបន្ស៊ាំសម្រាប់បណ្តាប្រទេសអភិវឌ្ឍតិចតួច នៅក្រោមមូលនិធិអាកាសធាតុបៃតង (Green Climate Fund)។

10. កម្ពុជាសូមគាំទ្រចំពោះកាតព្វកិច្ចដំណាក់កាលទី២ នៃពិធីសារក្យូតូ ហើយសុំធ្វើឱ្យមានភាពងាយស្រួលជាងមុន នូវនីតិវិធីនានាសម្រាប់អនុវត្តគម្រោងយន្តការអភិវឌ្ឍន៍ស្អាត ដើម្បីឲ្យប្រទេសអភិវឌ្ឍតិចតួច បានចូលរួមអនុវត្តគម្រោងយន្តការអភិវឌ្ឍន៍ស្អាតដោយពេញលេញ។ ជាងនេះទៅទៀត កម្ពុជាជម្រុញឲ្យភាគីទាំងអស់យកចិត្តទុកដាក់ចំពោះការបង្កើតយន្តការថ្មីៗ និងវិធីសាស្ត្រនានា ស្ថិតនៅក្រោមសមត្ថកិច្ចនៃអនុសញ្ញា UNFCCC ដើម្បីធានាបាននូវការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ជាដុំកំភួន។

11. កម្ពុជាគាំទ្រដល់ការអនុវត្ត សកម្មភាពជាតិសមស្របសម្រាប់កាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់នៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍ (Nationally Appropriate Mitigation Action: NAMAs) ក៏ប៉ុន្តែ សកម្មភាពកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់នេះត្រូវតែអាចវាស់វែងបាន រាយការណ៍បាន និងផ្ទៀងផ្ទាត់បាន (MRV)។ ការអនុវត្ត NAMAs ត្រូវធ្វើឡើងដោយស្ម័គ្រចិត្ត និងអនុលោមទៅតាមអាទិភាពនានារបស់ប្រទេសនីមួយៗ ហើយត្រូវតែមានការឧបត្ថម្ភគាំទ្រផ្នែកកសាងសមត្ថភាព ហិរញ្ញវត្ថុ និងការផ្ទេរបច្ចេកវិទ្យាពីបណ្តាប្រទេសអភិវឌ្ឍ។

12. កម្ពុជាទទួលស្គាល់នូវសារៈសំខាន់នៃវិធីសាស្ត្រ និងនីតិវិធីនានា ដែលមានការឯកភាពគ្នា សម្រាប់អនុវត្តការកាត់បន្ថយបញ្ចេញឧស្ម័នពីការបាត់បង់ និងរេចរិលព្រៃឈើ នៅក្នុងប្រទេសកំពុងអភិវឌ្ឍ រួមទាំងការគ្រប់គ្រងព្រៃឈើដោយចីរភាព ការអភិរក្សព្រៃឈើ និងការបង្កើនសន្និធិកាបូនក្នុងព្រៃឈើ (REDD+)។ នៅក្នុងបរិបទនេះ វិធីសាស្ត្រ និងនីតិវិធីនានា គួរត្រូវបានរៀបចំឡើង និងអនុម័តដោយសន្និសីទកំពូល (COP)។

13. កម្ពុជាសូមគាំទ្រដល់ការផ្តល់ហិរញ្ញប្បទានថ្មី បន្ថែម និងអាចព្យាករណ៍បាន ពីប្រភពសាធារណៈរបស់បណ្តាប្រទេសក្នុងឧបសម្ព័ន្ធទី១ ហើយមូលនិធិសាធារណៈទាំងអស់នោះ ត្រូវតែទទួលបានដោយផ្ទាល់ និងដោយងាយស្រួល។ វិស័យឯកជន តាមរយៈយន្តការផ្អែកលើទីផ្សារ ត្រូវតែបំពេញបន្ថែម ឬបង្កើនហិរញ្ញវត្ថុសាធារណៈ។ ថវិកាបដិភាគ មិនគួរក្លាយជាឧបសគ្គ ឬជាលក្ខខណ្ឌសម្រាប់បណ្តាប្រទេសកំពុងអភិវឌ្ឍ ក្នុងការទទួលបាននូវរាល់មូលនិធិ ឬហិរញ្ញប្បទានទាំងអស់នោះទេ។

14. កម្ពុជាលើកទឹកចិត្តដល់បណ្តាប្រទេសអភិវឌ្ឍន៍ឱ្យពង្រឹងការប្តេជ្ញាចិត្ត និងបង្កើនការគាំទ្រផ្នែកហិរញ្ញវត្ថុរបស់ពួកគេដល់បណ្តាប្រទេសដែលងាយរងគ្រោះដោយការប្រែប្រួលអាកាសធាតុ ជាពិសេសប្រទេសអភិវឌ្ឍតិចតួច។

15. កម្ពុជាសូមអំពាវនាវឲ្យមានផែនទីបង្ហាញផ្លូវហិរញ្ញវត្ថុដ៏ច្បាស់លាស់មួយ ដើម្បីផ្តល់នូវហិរញ្ញប្បទានសាធារណៈថ្មី បន្ថែម និងអាចទស្សន៍ទាយបាន ដល់ប្រទេសបណ្តាកំពុងអភិវឌ្ឍ ដើម្បីបំពេញសេចក្តីត្រូវការក្នុងចន្លោះឆ្នាំ២០១៣-២០២០។

16. កម្ពុជាលើកទឹកចិត្តដល់បណ្តាប្រទេសអភិវឌ្ឍ ឲ្យផ្តល់ការគាំទ្រហិរញ្ញប្បទានប្រចាំឆ្នាំ ដល់បណ្តាប្រទេសកំពុងអភិវឌ្ឍ ឲ្យបាន១០០ពាន់លានដុល្លារអាមេរិក នៅត្រឹមឆ្នាំ២០២០ ដូចដែលមានចែងក្នុងកិច្ចព្រមព្រៀងទីក្រុងកូប៉េនហាក។

17. កម្ពុជាគាំទ្រការវាយតម្លៃលើតម្រូវការបច្ចេកវិទ្យា ជាពិសេសតម្រូវការជាបន្ទាប់សម្រាប់អភិវឌ្ឍ និងផ្ទេរបច្ចេកវិទ្យានានាសម្រាប់ការបន្ស៊ាំ នៅគ្រប់ភាគីនៃប្រទេសកំពុងអភិវឌ្ឍ ជាពិសេសបណ្តាប្រទេសអភិវឌ្ឍតិចតួច។

លើសពីនេះទៀត ផែនការសកម្មភាពបច្ចេកវិទ្យា គួរតែត្រូវបានរៀបចំឡើង និងអនុវត្ត ដោយមានការគាំទ្រពីបណ្តាប្រទេសអភិវឌ្ឍ។ បច្ចេកវិទ្យាដែលផ្ទេរ គួរតែសមស្រប និងមានមេត្រីភាពជាមួយបរិស្ថាន ដោយផ្អែកលើអាទិភាពនានារបស់ប្រទេសជាម្ចាស់ផ្ទះ។

18. កម្ពុជាស្វាគមន៍ដល់ការបង្កើតគណៈកម្មាធិការប្រតិបត្តិផ្នែកបច្ចេកវិទ្យា (Technology Executive Committee: TEC) ក៏ដូចជាមជ្ឈមណ្ឌលបច្ចេកវិទ្យាអាកាសធាតុ និងបណ្តាញការងារ (Technology Centers and Networks: CTCN)។ CTCN គួរតែសកម្មបន្ថែមទៀតក្នុងការផ្តល់ការគាំទ្របច្ចេកវិទ្យាដល់បណ្តាប្រទេសកំពុងអភិវឌ្ឍ ជាពិសេសប្រទេសអភិវឌ្ឍតិចតួច។
19. កម្ពុជាគាំទ្រដល់វិធានការដោយឡែក និងបន្ទាន់នានា ដើម្បីលុបបំបាត់របាំងដែលកើតចេញពីកម្មសិទ្ធិបញ្ញាលើបច្ចេកវិទ្យាដែលមានមេត្រីភាពជាមួយបរិស្ថាន នៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍ និងប្រទេសអភិវឌ្ឍតិចតួច។
20. កម្ពុជាគាំទ្រដល់ការបង្កើនសកម្មភាពនានាលើការកសាងសមត្ថភាព ដើម្បីកែលម្អឱ្យប្រសើរឡើងនូវសមត្ថភាព និងលទ្ធភាពនៃបណ្តាប្រទេសកំពុងអភិវឌ្ឍ។ ការកសាងសមត្ថភាពត្រូវតែជាដំណើរការជាប់បន្តជាប្រចាំ តាមតម្រូវការរបស់ប្រទេសនីមួយៗ មានការចូលរួមយ៉ាងពេញលេញ និងជាដំណើរការពង្រឹងសកម្មភាពគ្រប់ជ្រុងជ្រោយ។
21. កម្ពុជាគាំទ្រដល់សកម្មភាពនានាដែលផ្តល់សិទ្ធិអំណាច និងពង្រឹងស្ថាប័ននានា ដែលពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ រួមទាំងជនបង្គោល និងស្ថាប័នសម្របសម្រួលនានារបស់ជាតិ។
22. កម្ពុជាគាំទ្រដល់តម្រូវការចាំបាច់សម្រាប់ការកសាងសមត្ថភាព ដែលអាចវាស់វែងបាន តាមរយៈការប្រើប្រាស់សូចនាករសមិទ្ធិផលដែលមានប្រសិទ្ធភាព និងមានការឯកភាពគ្នា ហើយគ្រប់ភាគីទាំងអស់ត្រូវធ្វើសេចក្តីរាយការណ៍អំពីការរីកចម្រើននានាដែលបានធ្វើឡើង លើការបង្កើនសមត្ថភាពដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ ទៅក្នុងរបាយការណ៍ជាតិស្តីពីការប្រែប្រួលអាកាសធាតុរបស់ខ្លួន។